**ការរើសអើង ការស្អប់ខ្ពើមជនបរទេស ការប្រកាន់ពូជសាសន៍**

- ជំងឺរាតត្បាតកូវីដ-១៩ កំពុងបង្កើតឱ្យមានរលកនៃការមាក់ងាយ ការរើសអើង ជាតិសាសន៍និយម និងការស្អប់ខ្ពើមជនបរទេស ប្រឆាំងនឹងក្រុមជាតិ និងជាតិពន្ធុមួយចំនួន។ យើងត្រូវធ្វើការរួមគ្នាដើម្បីទប់ទល់នឹងនិន្នាការនេះ រួមទាំងការសំដៅទៅលើជំងឺនេះថាជាជំងឺកូវីដ-១៩ ជាជាងការប្រើប្រាស់ពាក្យពេចន៍ដែលយោងដល់តំបន់ភូមិសាស្ត្រ។
- មេដឹកនាំនយោបាយ និងឥស្សរជនដែលមានឥទ្ធិពលដទៃទៀត គួរតែថ្លែងសន្ធរកថាខ្លាំងៗពូជសាសន៍ដែលវិបត្តិនេះបានបង្កើតឡើង ហើយត្រូវតែជៀសវាងដាច់ខាត ក្នុងដុតបញ្ឆេះឱ្យមានការរើសអើងបែបនេះ។ រដ្ឋទាំងឡាយ គួរតែចាត់វិធានការជាបន្ទាន់ ដើម្បីប្រឆាំងនឹងវោហារសាស្ត្រដែលបង្កការភ័យខ្លាច ហើយធានាថារាល់ការឆ្លើយតបរបស់ខ្លួន ទៅនឹងជំងឺកូវីដ-១៩ មិនធ្វើឱ្យក្រុមមនុស្សជាក់លាក់មួយចំនួនកាន់តែងាយរងគ្រោះថែមទៀត ដោយអំពើហិង្សា និងការរើសអើងនោះឡើយ។
- ការផ្សព្វផ្សាយនូវព័ត៌មានពិត ច្បាស់លាស់ និងផ្អែកលើភស្តុតាង និងយុទ្ធនាការលើកកម្ពស់ការយល់ដឹង គឺជាឧបករណ៍ដែលមានប្រសិទ្ធភាពបំផុត ប្រឆាំងនឹងការរើសអើង និងការស្អប់ខ្ពើមជនបរទេស ដែលសំអាតចេញនូវព័ត៌មានមិនពិត និងការភ័យខ្លាច។ ត្រូវមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីឃ្លាំមើលឧប្បត្តិហេតុនៃការរើសអើង និងការស្អប់ខ្ពើមជនបរទេស និងឆ្លើយតបទៅនឹងឧប្បត្តិហេតុណាមួយ គួរតែត្រូវបានផ្សព្វផ្សាយឱ្យបានឆាប់រហ័ស និងត្រឹមត្រូវ។